# ខែតុលា ឆ្នាំ 2024

King County
Department of Natural Resources and Parks
Wastewater Treatment Division

Mouth of Duwamish
CSO PROGRAM

# ការរាយការណ៍ត្រឡប់មកវិញនៅរដូវក្តៅ ឆ្នាំ 2024 អំពីមតិរបស់សហគមន៍!



## របាយការសង្ខេប

King County Wastewater Treatment Division (WTD) នាយកដ្ឋានប្រព្រឹត្តិកម្មទឹកសំណល់នៃខោនធី King កំពុងធ្វើការដើម្បីគ្រប់គ្រងលំហូរទឹកស្អុយរួមបញ្ចូលគ្នា (CSO) ពីប្រភពទឹកលេចចេញចំនួនប្រាំនៅមាត់ទន្លេ Duwamish Waterway។ ក្នុងអំឡុងដំណាក់កាលរៀបចំផែនការ ខោនធី King នឹងពិចារណាលើមតិយោបល់ ដែលប្រមូលបានពីសហគមន៍ដើម្បីកំណត់ដំណោះស្រាយដ៏ល្អបំផុតដើម្បីគ្រប់គ្រងការលេចចេញនៃ CSO និងបំពេញតាមតម្រូវការបទប្បញ្ញត្តិ និងបរិស្ថាន។

នៅចន្លោះថ្ងៃទី 1 ខែមិថុនា និងថ្ងៃទី 31 ខែសីហា ឆ្នាំ 2024 ខោនធី King បានធ្វើព្រឹត្តិការណ៍សម្រាប់ការចូលរួមពីសហគមន៍ដើម្បីចែករំលែកព័ត៌មានអំពីបរិក្ខារគ្រប់គ្រងអាកាសធាតុសើមនៅមាត់ទន្លេ Duwamish និងឮពីសមាជិកសហគមន៍ដែលរស់នៅ ធ្វើការ និងធ្វើដំណើរឆ្លងកាត់ SODO និង West Seattle (Industrial District West) យើងទទួលបានការចូលរួមពីមនុស្សជិត 2,000 នាក់។

### របៀបដែលយើងទទួលបានការចូលរួម៖

- បទសម្ភាសន៍អំពីគុណតម្លៃសហគមន៍ចំនួនបួន
- ព្រឹត្តិការណ៍ផ្សព្វផ្សាយដោយផ្ទាល់ចំនួនបួន
- សេចក្តីសង្ខេបរបស់ភាគីដែលចាប់អារម្មណ៍ចំនួនប្រាំ
- កិច្ចប្រជុំបើកចំហតាមអនឡាញមួយ និងការស្ទង់មតិ
- កិច្ចប្រជុំសាធារណៈតាមប្រព័ន្ធនិម្មិតចំនួនពីរ

### របៀបដែលយើងបានចែករំលែក៖

- ការចែកចាយបណ្ណប្រកាសដល់មាត់ទ្វារផ្ទះ
- ព័ត៌ថ្មីៗនៃបញ្ជីអ៊ីមែល
- ការផ្សព្វផ្សាយដល់អង្គការតាមសហគមន៍
- ការផ្ញើបណ្ណប្រៃសណីយ៍
- ប្រព័ន្ធផ្សព្វផ្សាយសង្គម
- ព័ត៌មានថ្មីៗតាមគេហទំព័រ

### ភាសាដែលយើងបានប្រើ៖

- ភាសាចិន (សាមញ្ញ និងបុរាណ)
- ភាសាអង់គ្លេស
- ភាសាខ្មែរ
- ភាសាអេស្ប៉ាញ
- ភាសាវៀតណាម

## លទ្ធផល

ភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយ មនុស្ស 386 នាក់

ការមើលកិច្ចប្រជុំបើកចំហតាមអនឡាញ 1502 ដង

អ្នកចូលរួមកិច្ចប្រជុំសាធារណៈតាមប្រព័ន្ធនិម្មិតចំនួន 12 នាក់

ការឆ្លើយតបការស្ទង់មតិ ចំនួន 37

## អ្វីដែលយើងបានឮ

សកម្មភាពនីមួយៗនៅក្នុងស៊េរីនៃកិច្ចប្រជុំបើកចំហរួមមានឱកាសសម្រាប់អ្នកចូលរួមដើម្បីចែករំលែកការយល់ដឹងរបស់ពួកគេអំពីគុណតម្លៃសហគមន៍ កត្តាដែលខោនធី King នឹងពិចារណានៅពេលកំណត់សម្គាល់ដំណោះស្រាយដ៏ល្អបំផុត និងយុទ្ធសាស្រ្តចូលរួមរបស់សហគមន៍។



| អ្វីដែលយើងបានឮ | របៀបដែលយើងប្រើវា |
|---|---|
| លទ្ធភាពទទួលបានការដឹកជញ្ជូនប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព សន្តិសុខសហគមន៍ និងសាធារណៈ បរិស្ថានបែបធម្មជាតិ និងបង្កើតឱ្យមានសុខភាពល្អ ការងារដែលប្រាក់ឈ្នួលអាចទ្រទ្រង់គ្រួសារបាន និងការបណ្តុះបណ្តាលការងារ និងសង្កាត់ដ៏រឹងមាំ គឺជាអាទិភាពទាំងអស់សម្រាប់សមាជិកសហគមន៍នៅក្នុងតំបន់គម្រោង។ | ការគាំទ្រចក្ខុវិស័យ និងគោលដៅរបស់សហគមន៍របស់យើងស្របតាមផែនការយុទ្ធសាស្រ្តយុត្តិធម៌សង្គម និងសមធម៌របស់យើង។ នៅពេលដែលយើងធ្វើការដើម្បីផ្តល់គម្រោងដែលការពារដល់សុខភាពសាធារណៈ និងបរិស្ថាន យើងនឹងគាំទ្រគំនិតផ្តួចផ្តើមដែលជំរុញដោយសហគមន៍ និងវាយតម្លៃសក្តានុពលចំពោះដំណោះស្រាយដែលអាចធ្វើទៅបាននីមួយៗ ដើម្បីផ្តល់អត្ថប្រយោជន៍ស្របតាមតម្លៃរបស់សង្កាត់ទាំងនេះ។ នៅក្នុងដំណើរការរចនានេះ យើងនឹងស្វែងរកឱកាសដើម្បីរួមបញ្ចូលអាទិភាពទាំងនេះ។ |
| សមាជិកសហគមន៍ចង់ឃើញការកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់អ្នកថ្មើរជើង ខ្យល់ស្អាត និងលទ្ធភាពទទួលបានកន្លែងដែលមានរុក្ខជាតិបៃតង និងដើមឈើ និងឱកាសកម្សាន្តកាន់តែច្រើននៅក្នុង SODO និង West Seattle (Industrial District West)។ | ក្រុមការងាររបស់យើងនឹងរួមបញ្ចូលធាតុទាំងនេះនៅក្នុងបរិក្ខារគ្រប់គ្រងអាកាសធាតុសើមនៅមាត់ទន្លេ Duwamish តាមដែលអាចធ្វើទៅបានក្នុងអំឡុងពេលនៃការរចនា។ |
| សមាជិកសហគមន៍មានចំណាប់អារម្មណ៍ក្នុងការស្វែងយល់បន្ថែមអំពីកត្តាទាំងអស់ដែលស្ថិតក្រោមការពិចារណាក្នុងអំឡុងពេលកិច្ចខិតខំប្រឹងប្រែងរបស់ខោនធី King ដើម្បីកំណត់ដំណោះស្រាយដ៏ល្អបំផុត។ | នៅពេលដែលខោនធី King កំណត់ឃើញដំណោះស្រាយដ៏ល្អបំផុតសម្រាប់ការងារនេះ យើងនឹងពន្យល់ពីរបៀប ដែលយើងរំពឹងថាគម្រោងនឹងត្រូវអនុវត្តទាក់ទងនឹងផលប៉ះពាល់សហគមន៍ និងសង្គម ផលប៉ះពាល់លើបរិស្ថាន ប្រតិបត្តិការ និងការថែទាំជួសជុល តម្លៃ និងកាលវិភាគ។ |
| មានគម្រោងជាច្រើន ដែលបានគ្រោងទុកនៅក្នុងតំបន់គម្រោង ហើយសមាជិកសហគមន៍នឹងមានអារម្មណ៍ថាមានផលប៉ះពាល់ពីការសាងសង់។ | ក្រុមការងាររបស់យើងនឹងអនុវត្តវិធីសាស្រ្តសម្របសម្រួលជាមួយ Sound Transit និងនាយកដ្ឋាន Seattle Department of Transportation ដើម្បីជួយកាត់បន្ថយការចំណាយកម្លាំងក្នុងការសាងសង់ និងធ្វើឱ្យវាកាន់តែងាយស្រួលសម្រាប់សមាជិកសហគមន៍ក្នុងការទទួលបានព័ត៌មានដែលពួកគេត្រូវការ។ |

ដើម្បីមើលចម្លើយចំពោះសំណួរទូទៅដែលខោនធី King ទទួលបានក្នុងដំណាក់កាលនៃការផ្សព្វផ្សាយនេះ
សូមរកមើលផ្នែកសំណួរដែលគេសួរញឹកញាប់ក្នុងដំណាក់កាលរៀបចំផែនការរបស់យើង។

## តើមានអ្វីបន្ទាប់ទៀត?

នៅដើមឆ្នាំ 2025 ខោនធី King នឹងកំណត់រកដំណោះស្រាយដ៏ល្អបំផុតដើម្បីកាត់បន្ថយ CSO នៅមាត់ទន្លេ Duwamish ត្រង់ចំណុចបង្ហូរទឹកចេញទាំងប្រាំ។ នៅពេលនោះ យើងនឹងចែករំលែកព័ត៌មានតាមរយៈការរៀបចំវគ្គព័ត៌មានដោយមិនចំបាច់ចុះឈ្មោះ ការចែករំលែកអ៊ីមែល និងការសង្ខេបជាមួយអង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍ ការបោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មានរបស់គម្រោង និងផ្ញើតាមបញ្ជីអ៊ីមែល ព័ត៌មានថ្មីៗនៅលើគេហទំព័ររបស់យើង និងការបង្ហោះព័ត៌មាននៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។

## ទាក់ទងមកយើងខ្ញុំ

បើមានសំណួរ ឬដើម្បីកំណត់ពេលវេលាផ្តល់សេចក្តីសង្ខេបដល់ស្ថាប័នរបស់អ្នក សូមទាក់ទង Bibiana Ocheke-Ameh តាមរយៈអ៊ីមែល **Bibiana.Ocheke-Ameh@kingcounty.gov** ឬលេខទូរសព្ទ **206-477-5604**។

សូមចូលមើលគេហទំព័រ **kingcounty.gov/MDWetWeatherFacilities** ដើម្បីស្វែងយល់ពីព័ត៌មានចុងក្រោយបំផុតអំពីគម្រោង ចូលមើលឯកសាររបស់គម្រោងទាំងអស់ និងចូលរួមក្នុងបញ្ជីក្រុមអ៊ីមែលរបស់យើង។